# ទំនប់ដនសាហុង និងជលផលនៃទន្លេមេគង្គ


អត្ថបទវិទ្យាសាស្ត្រសង្ខេបពីមជ្ឈមណ្ឌល WorldFish Center

ដោយ អេរិក បារ៉ាន និង ប្លេក រ៉ាតន័រ (Eric Baran & Blake Ratner)



ខែ មិថុនា ឆ្នាំ ២០០៧


WorldFish CENTER

## *សារគន្លឹះ*

- ប្រសិនបើកសាងមែននោះ ទំនប់ដនសាហុង គឺជាទំនប់ដំបូងគេ នៅខ្សែទឹកខាងលើនៃទន្លេមេគង្គក្រោម។
- ដៃទន្លេហ៊ូសាហុង ដែលជាកន្លែងស្នើកសាងទំនប់ មានមុខងារសំខាន់សម្រាប់ត្រីធ្វើចរាចរនៅក្នុងអាងទន្លេនេះទាំងមូល។
- អាងទន្លេមេគង្គក្រោម ជាកន្លែងសំបូរធនធានជលផលទឹកសាបជាងគេបំផុតនៅលើពិភពលោក និង រួមចំណែកយ៉ាងច្រើនចំពោះសេដ្ឋកិច្ចជាតិ និងតំបន់ ចំពោះសន្តិសុខស្បៀង និងជីវភាពរស់នៅតាមជនបទ។
- នៅក្នុងតំបន់នេះ គេពុំមានវិធានការប្រកបដោយប្រសិទ្ធិភាពដើម្បី កាត់បន្ថយផលប៉ះពាល់នៃទំនប់ មកលើធនធានជលផលឡើយ។
- ការខាតបង់ផ្នែកសេដ្ឋកិច្ចបណ្តាលពីការបាត់បង់ធនធានជលផល អាចមានទំហំធំជាងផលចំណេញខាងសេដ្ឋកិច្ចដែលរំពឹងថាបានមកពីទំនប់នេះទៅទៀត។ គេចាំបាច់ត្រូវធ្វើការសិក្សាទូលំទូលាយបែបវិទ្យាសាស្ត្រ ដើម្បីវាយតម្លៃបញ្ហានេះ។

## សេចក្តីផ្តើម

ទំនប់នាំមកនូវអត្ថប្រយោជន៍សេដ្ឋកិច្ចសំខាន់ៗសម្រាប់វិស័យមួយចំនួននៃសេដ្ឋកិច្ចជាតិ និងតំបន់។ ទោះជាយ៉ាងណាក៏ដោយ ការកសាងទំនប់ក៏នាំមកនូវការខាតបង់យ៉ាងច្រើនខាងផ្នែកសេដ្ឋកិច្ចចំពោះវិស័យដទៃទៀតផងដែរ។ ជលផល គឺជាវិស័យមួយក្នុងចំណោមវិស័យសំខាន់បំផុត ដែលនឹងត្រូវរងគ្រោះដោយការកសាងទំនប់ទឹក ដូច្នេះដើម្បីទាញយកសក្តានុពលសេដ្ឋកិច្ចពីទន្លេមួយឱ្យបានពេញលេញ គេត្រូវយល់ដឹងឱ្យបានគ្រប់ជ្រុងជ្រោយពីវិស័យនេះ។ អត្ថបទវិទ្យាសាស្ត្រសង្ខេបនេះ ពិនិត្យមើលព័ត៌មាននានាអំពីផលប៉ះពាល់ដែលអាចកើតឡើង បណ្តាលពីសំណើកសាងទំនប់វារីអគ្គិសនីដនសាហុង មកលើធនធានជលផលនៃអាងទន្លេមេគង្គភាគ ខាងក្រោម។




*រូបទី ១: ទីតាំងសំណើសាងសង់ទំនប់* [3]

## ទំនប់ដនសាហុង

រដ្ឋាភិបាលឡាវ និងក្រុមហ៊ុនធំមួយឈ្មោះ Mega First Corporation Berhad (MFCB) ដែលជាក្រុមហ៊ុនវិស្វកម្មម៉ាឡេស៊ីមួយ បានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់មួយ កាលពីខែ មីនា ឆ្នាំ ២០០៦ លើគម្រោងថាមពលវារីអគ្គិសនីដនសាហុង[1] ។ ប្រធានក្រុមហ៊ុន MFCB បានឱ្យដឹងថា គម្រោងនេះដែលមានទឹកប្រាក់ ៣០០ លានដុល្លាអាមេរិក ត្រូវបានគ្រោងសាងសង់រួចរាល់នៅឆ្នាំ ២០១០ និងមានសមត្ថភាពផលិតអគ្គិសនី ២៤០ មេហ្គាវ៉ាត់។ នាយកក្រុមហ៊ុននេះបានឱ្យដឹងថា "នេះគឺជាគម្រោងទំនប់បង្វែរដែលយើងនឹងសង់ទំនប់មួយនៅលើដៃមួយនៃទន្លេនេះ"[2] ។ ទោះបីពុំមានការផ្សព្វផ្សាយលក្ខណៈបច្ចេកទេសផ្នែកវិស្វកម្មជាសាធារណៈក្តី គម្រោងនេះនឹងមានសមត្ថភាពច្រើនជាងបួនដង ធំជាងគម្រោងមួយ ដែលគេធ្លាប់បានគ្រោងសង់នៅត្រង់ទីតាំងនោះ និងគ្រោងឱ្យមានកំពស់ ២៦ ម៉ែត្រ[3] ។ ប្រសិនបើទំនប់ នេះត្រូវបានសង់មែននោះ វានឹងក្លាយជាទំនប់ដំបូងបង្អស់នៅលើផ្លូវទឹកមេនៃដងទន្លេមេគង្គក្រោម។

## សារៈសំខាន់នៃល្បាក់ខោន និងហ៊ូសាហុង

ល្បាក់ខោន គឺជាកន្លែងសំខាន់មួយសម្រាប់ធនធានមច្ឆជាតិ នៃទន្លេមេគង្គទាំងមូល។ នៅត្រង់ល្បាក់នេះ ទឹកទន្លេមេគង្គហូរធ្លាក់ចុះកំពស់ ២០-៣០ ម៉ែត្រ ពីខ្ពង់រាបកូរ៉ាតមកកាន់ទំនាបទន្លេមេគង្គ។ នៅទីនេះទន្លេមេគង្គបង្កើតជាបណ្តាញដៃទន្លេតូចៗហូរចាក់ស្រេះគ្នា ដែលភាសាឡាវហៅថា *ហ៊ូ*។ អ្នកវិទ្យាសាស្ត្របានចងក្រងជាឯកសារអំពីតំបន់នេះយ៉ាងហ្មត់ចត់ និងបានរកឃើញថា កន្លែងនេះទ្រទ្រង់ការរស់នៅរបស់ត្រី យ៉ាងហោចណាស់ចំនួន ២០១ប្រភេទដែរ ដែលរាប់ទាំងប្រភេទត្រីដែលមាននៅតែក្នុងតំបន់នេះ ឬ ប្រភេទត្រីជិតផុតពូជផងដែរ ដែលមានឈ្មោះថា "ប៉ាសេអ៊ី" (*Mekongina erythrospila*) និង "ត្រីត្រសក់" (*Probarbus jullieni*)[4] ។ ទីនេះក៏ជាកន្លែង




*រូបទី ២: តំបន់ល្បាក់ខោន*

ដែលទ្រទ្រង់ដល់ការរស់នៅនៃសត្វផ្សោតទឹកសាប (*Orcaella brevirostris*) ដែលមាននៅសល់ក្នុងចំនួនតិចតួចក្នុងទន្លេមេគង្គផងដែរ។

ក្នុងចំណោមការសិក្សាសំខាន់ៗ មានការសិក្សាវិទ្យាសាស្ត្រចំនួន ២៨ លើក ដែលបង្ហាញថាកន្លែងនេះមានតួនាទីជាច្រកតូចមួយសម្រាប់ការធ្វើចរាចររបស់ត្រីនៅក្នុងអាងទន្លេនេះ[5] ។ ហ៊ូសាហុង ដែលជាកន្លែងគ្រោងសង់ទំនប់មានសារៈសំខាន់ណាស់ ព្រោះវាមានតួនាទីដោយឡែកមួយសម្រាប់ត្រីធ្វើចរាចរ។ អត្ថបទមួយដែលចុះផ្សាយក្នុងព្រឹត្តិបត្រព័ត៌មានរបស់គណៈកម្មការទន្លេមេគង្គ ជាងមួយទសវត្សកន្លងទៅ បានពណ៌នាអំពីប្រការនេះយ៉ាងពិស្តារថា[6] :

*នៅខែមេសា ក្រុមដំបូងនៃពពួកត្រីមានពុកមាត់ធ្វើដំណើរ ពីកម្ពុជាមកដល់ល្បាក់ខោន។ គេនេសាទត្រី "ឈ្វៀត" (Pangasius macronema) បានយ៉ាងច្រើន នៅពេលដែលត្រីទាំងនោះធ្វើដំណើរច្រាសចរន្តទឹកទន្លេមេគង្គ ឆ្លងផុតល្បាក់ទឹកនានា។ ត្រីប្រភេទទាំងនេះ ដែលមានសារៈសំខាន់ខាងផ្នែកសេដ្ឋកិច្ចត្រូវគេនេសាទបានយ៉ាងច្រើន ជាពិសេសនៅតាមដងទន្លេហ៊ូសាហុងនៃតំបន់ល្បាក់ខោន ដែលស្ថិតនៅចន្លោះកោះដនសាដាំ និង ដនសាហុង។ នេះដោយសារហ៊ូសាហុង គឺជាផ្លូវទឹកតែមួយគត់ដែលផ្តល់ប្រសិទ្ធិភាពខ្ពស់ សម្រាប់ត្រីទាំងនេះផ្លាស់ទីឆ្លងល្បាក់ខោននៅរដូវដែលមានទឹករាក់។ តាមពិត អ្នកមូលដ្ឋាននៅទីនោះសុទ្ធតែស្គាល់ និងដឹងថាហ៊ូសាហុងជាផ្លូវទឹកដ៏សំខាន់បំផុតសម្រាប់ត្រីធ្វើចរាចរច្រាសចរន្តទឹកហូរនៅគ្រប់រដូវ។ ផ្លូវទឹកដទៃទៀតភាគច្រើននៅតំបន់ល្បាក់ខោន សុទ្ធតែមានល្បាក់ទឹកធំៗ ដែលមិនអាចឱ្យត្រីធ្វើចរាចរឆ្លងកាត់បាន។ ម្យ៉ាងវិញទៀតនៅលើដងទន្លេហ៊ូសាហុង ដែលមានប្រវែងប្រមាណ ៧ គ.ម ពុំមានរបាំងធម្មជាតិឡើយ ដែលបង្កលក្ខណៈងាយស្រួលសម្រាប់ត្រី ដែលធ្វើចរាចរពីកម្ពុជាឆ្លងកាត់តំបន់ល្បាក់ខោន។*

*... រដ្ឋាភិបាលឡាវ បានពិចារណាជាយូរមកហើយថាដៃទន្លេនេះមានសារៈសំខាន់ជាពិសេសសម្រាប់ត្រីធ្វើចរាចរ។ ក្នុងអំឡុងពេលខុសៗគ្នានៃទសវត្សឆ្នាំ១៩៦០ ១៩៧០ និង ១៩៨០ រដ្ឋាភិបាលឡាវបានហាមឃាត់ការនេសាទត្រីនៅហ៊ូសាហុង ដោយសារមុខនាទីដ៏ល្បីល្បាញនៃទន្លេនេះ ដែលជាគន្លងផ្លូវមួយសម្រាប់ត្រីធ្វើចរាចរ។ អ្នកភូមិដែលរស់នៅប៉ែកខាងលើទន្លេហ៊ូសាហុង តែងនិយាយជារឿយៗថា ប្រសិនបើត្រីមិនអាចឆ្លងកាត់ដៃទន្លេនេះទេ អ្នកទាំងឡាយដែលរស់នៅចាប់ពីស្រុកខោន រហូតដល់ប៉ែកខាងជើងក្រុងវៀងច័ន្ទ នឹងពុំមានត្រីគ្រប់គ្រាន់សម្រាប់ទទួលទានឡើយ ព្រោះថាត្រីមិនអាចធ្វើចរាចរឆ្លងកាត់ដៃទន្លេដទៃទៀត នៅតំបន់ល្បាក់ខោនបានដោយងាយក្នុងបរិមាណច្រើនដូចនេះបានឡើយ។*

*...ការបិទច្រកហ៊ូសាហុង អាចធ្វើឱ្យវិនាសហិនហោចធនធានជលផលសំខាន់ៗភាគច្រើននៃទន្លេមេគង្គក្នុងប្រទេសឡាវ។*




*រូបទី ៣: ទម្រង់នៃការធ្វើចរាចររបស់ត្រីនៅតំបន់ល្បាក់ខោន។ Adapted from Baran 2006*

ទំនប់មួយលើដៃទន្លេហ៊្វូសាហុង នឹងធ្វើឱ្យស្ទះផ្លូវទឹកដែលជ្រៅជាងគេតែមួយគត់ ដែលធ្លាប់តែអាចឱ្យត្រីឆ្លងកាត់ល្បាក់ទឹកនេះនៅគ្រប់រដូវ។ សំណង់នេះនឹងរាំងស្ទះការធ្វើចរាចររបស់ត្រីនៅរដូវប្រាំងរវាងទំនាបទន្លេមេគង្គក្រោម និងអាងទន្លេមេគង្គភាគខាងលើ។ ដូចមានបង្ហាញនៅក្នុងរូបទី ៣ រដូវប្រាំងគឺជាពេលសំខាន់បំផុតសម្រាប់ត្រីផ្លាស់ទីទៅតំបន់ខ្សែទឹកខាងលើ។ នៅក្នុងអាងមេគង្គ ៨៧ ភាគរយនៃប្រភេទត្រីដែលគេដឹងអំពីស្ថានភាពផ្លាស់ទីរបស់វា រួមទាំងប្រភេទត្រីដែលមានតម្លៃខ្ពស់សម្រាប់ពាណិជ្ជកម្មផងនោះ គឺជាប្រភេទផ្លាស់ទីរយៈឆ្ងាយ[7] ។ ជាទូទៅ ត្រីផ្លាស់ទីពីកន្លែងរកចំណីនៅតំបន់ខ្សែទឹកខាងក្រោម (បឹងទន្លេសាប តំបន់ទំនាបលិចទឹកនៅកម្ពុជា) ទៅតំបន់នៅខ្សែទឹកខាងលើដើម្បីបន្តពូជ (ភាគខាងជើងប្រទេសកម្ពុជា ឡាវ និងថៃ)។ ប្រពលភាពនៃការនេសាទនៅចុងរដូវប្រាំង ដែលផ្តល់ផលពី ១១ ទៅ ៧៣ ភាគរយនៃទិន្នផលសរុបប្រចាំឆ្នាំ នៅល្បាក់ខោន បង្ហាញជាបន្ថែមទៀតពីសារៈសំខាន់សម្រាប់ត្រីធ្វើចរាចរនៅក្នុងរយៈពេលប៉ុន្មានខែ ដែលទឹកមានកំពស់ទាបបំផុតនេះ។ ក្នុងចំណោមត្រីទាំងនេះ មានទាំងត្រីដែលធ្វើចរាចរទៅបន្តពូជផងដែរ[8] ។ ហេតុនេះ ការធ្វើឱ្យរាំងស្ទះដល់បម្លាស់ទីរបស់ត្រីនៅត្រង់ល្បាក់ខោន នឹងធ្វើឱ្យមានផលប៉ះពាល់ផ្នែកសង្គម បរិស្ថាន និងសេដ្ឋកិច្ចនៅទូទាំងអាងទន្លេនេះ។

ត្រីជាច្រើនប្រភេទ ក៏ឆាប់រងផលប៉ះពាល់ដោយសារការប្រែប្រួលនៃកំពស់ទឹកដែលជា "កត្តាជម្រុញ" ឱ្យត្រីធ្វើចរាចរផងដែរ។ ខណៈដែលសំណើទំនប់ទឹកដនសាហុងគឺជាគម្រោង "ទំនប់បង្វែរ" វានឹងធ្វើឱ្យលំនាំទឹកហូរប្រែប្រួលនៅភាគខាងក្រោមដែលស្ថិតនៅជាប់នឹងទីតាំង

គម្រោងនេះ ជាពិសេសក្នុងរដូវដែលមានទឹកតិចបំផុត។ ប្រការនេះក៏អាចធ្វើឱ្យខកខានដល់ការធ្វើចរាចររបស់ត្រីផងដែរ។ ការផ្លាស់ប្ដូររបបជលសាស្ត្រនេះ គឺជាសញ្ញាដែលជម្រុញឱ្យត្រីចំនួន ១៦ប្រភេទធ្វើចរាចរ ក្នុងនោះភាគច្រើនធ្វើឡើងនៅចុងរដូវប្រាំង។ ក្នុងចំណោមប្រទេសនៅតាមដងទន្លេមេគង្គ កម្ពុជាងាយរងគ្រោះជាងគេពីឥទ្ធិពលបែបនេះ។ ឧទាហរណ៍ ក្នុងចំណោមត្រី ១០ក្រុមដែលមានច្រើនលើសលុបនៅក្នុងផលនេសាទពីបឹងទន្លេសាប ត្រីចំនួន ៤ក្រុម ងាយរងឥទ្ធិពលពីកត្តាជម្រុញនៃរបបទឹកបែបនេះ។ ត្រីទាំង ៤ ក្រុមនេះ ផ្ដល់ជា ១៨ ភាគរយនៃទិន្នផលចាប់បានសរុបនៅបឹងទន្លេសាប និង ១៤ ភាគរយនៃតម្លៃផលចាប់នៅបឹងទន្លេសាប[9] ។ ក្រុមត្រីដែលងាយរងឥទ្ធិពលចំពោះកត្តាជម្រុញនៃរបបទឹករួមមានពពួកត្រីប្រា (Pangasiidae) ដែលមាន សារៈសំខាន់សម្រាប់ពាណិជ្ជកម្មទាំងខាងផ្នែកផលចាប់ និងផ្នែកវារីវប្បកម្ម។

## សារៈសំខាន់ផ្នែកសេដ្ឋកិច្ចនៃជលផលទន្លេមេគង្គ

ផលនេសាទពីធម្មជាតិ មានសារៈសំខាន់ចំពោះសេដ្ឋកិច្ចនៃប្រទេសឡាវ ដោយរួមចំណែកប្រមាណជា ៦ ទៅ ៨ ភាគរយនៃផលិតផលក្នុងស្រុកសរុប[10, 11] ។ យោងតាមការប៉ាន់ប្រមាណទូលំទូលាយចុងក្រោយបំផុតមួយ ផលចាប់បានពីធម្មជាតិនៅប្រទេសឡាវ ដោយគិតបញ្ចូលទាំងផលចាប់នៅតាមវាលស្រែផងដែរ) មាន ៦៤.៦០០ តោន ឬ ត្រូវជា ៧៨ ភាគរយនៃផលិតផលត្រីសរុបក្នុងប្រទេស[10]។ ការស្រាវជ្រាវបានប៉ាន់ប្រមាណតម្លៃផ្ទាល់សម្រាប់សេដ្ឋកិច្ចក្នុងស្រុកថា មានពី ៦៦ លាន[12] ទៅ ១០០លាន[13] ដុល្លារអាមេរិកក្នុងមួយឆ្នាំ។

ការនេសាទមានសារៈសំខាន់ចំពោះជីវភាពរស់នៅ និងសន្តិសុខស្បៀង។ នៅភាគខាងត្បូងប្រទេសឡាវ ការបរិភោគត្រី និងអាហារដែលមានប្រភពពីដែនទឹកសាបមានពី ១៥ ទៅ ៥០ គ.ក្រ ក្នុងម្នាក់ៗ ក្នុងមួយឆ្នាំ[14] ។ នៅតាមបណ្ដាខេត្តជាប់ទន្លេមេគង្គ ផលិតផលត្រី និងជលផលផ្សេងទៀត រួមចំណែក ពី ២៧ ទៅ ៧៨ ភាគរយនៃប្រូតេអ៊ីនដែលបានពីសាច់សត្វនៅក្នុងរបបអាហាររបស់ប្រជាពលរដ្ឋ និងផ្ដល់ជាប្រភពសំខាន់មួយនៃសារធាតុមីក្រូអាហារូបត្ថម្ភ[14]។ ជំរឿនកសិកម្មចុងក្រោយបំផុតរបស់ប្រទេសឡាវបង្ហាញថា ជាងពាក់កណ្ដាលនៃចំនួនប្រជាជនឡាវ ចូលរួមក្នុងការនេសាទត្រីតាមរូបភាពប្លែកៗគ្នា។

នៅភាគខាងត្បូងនៃប្រទេសឡាវ ច្រើនជាង ៨០ ភាគរយ នៃចំនួនគ្រួសារសរុប ប្រកបរបរពាក់ព័ន្ធនឹងការនេសាទ ដោយផលចំណូលបានពីការប្រមូលធនធានពីក្នុងទឹករួមចំណែកប្រមាណ ២០ ភាគរយនៃចំណូលដុល[10] ។ នៅខែនានាដែលខ្សត់អង្ករ ប្រជាពលរដ្ឋពឹងផ្អែកលើត្រី និងអាហារដទៃទៀតដែលបានពីដែនទឹក ដើម្បីទប់ទល់នឹងការស្រេកឃ្លាន។ ប្រសិនបើគ្មានត្រីទេនោះ គ្រួសារភាគច្រើននឹងគ្មានជម្រើសណាផ្សេងដើម្បីទទួលបានអាហា

រូបត្ថម្ភឡើយ[15] ។ ការសិក្សាមួយនៅភាគខាងត្បូងប្រទេសឡាវបានសន្និដ្ឋានថា "ការនេសាទពុំមែនសំខាន់សម្រាប់តែពលរដ្ឋក្រីក្របំផុតនោះទេ ប៉ុន្តែជាផ្នែកសំខាន់មួយនៃជីវភាពរស់នៅរបស់គ្រួសារទាំងអស់"[16] ។

ផលនេសាទពីធម្មជាតិមានសារៈសំខាន់ចំពោះប្រទេសទាំងឡាយដែលស្ថិតនៅតាមដងទន្លេមេគង្គ ដោយផ្តល់តម្លៃជាទឹកប្រាក់ប្រចាំឆ្នាំ ២ ពាន់លានដុល្លារអាមេរិក[17] ។ អាងទន្លេមេគង្គក្រោម ដែលជាដែននេសាទទឹកសាបមានផលិតភាពខ្ពស់ជាងគេលើពិភពលោក ផ្តល់ផលចាប់ដល់ ២,៦ លានតោនក្នុងមួយឆ្នាំ ដែលត្រូវជាប្រាំដងច្រើនជាងផលនេសាទសរុបពីអាងស្តុកទឹក និងពីវារីវប្បកម្មរួមគ្នា[18] ។ វារីវប្បកម្ម រួមចំណែកត្រឹមតែ ១០ ទៅ ១២ភាគរយនៃផលត្រីនៅក្នុងអាងទន្លេមេគង្គទាំងមូលតែប៉ុណ្ណោះ[18, 19] ហើយអ្នកចិញ្ចឹមត្រី ច្រើនតែយកត្រីតូចៗដែលចាប់បានពីធម្មជាតិធ្វើជាចំណីសម្រាប់ត្រីចិញ្ចឹមរបស់ខ្លួន។ ដូចមានគូសបញ្ជាក់នៅក្នុងរបាយការណ៍ថ្មីៗមួយ ដែលរៀបរៀងដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាថា ការខាតបង់ធនធានជលផលសូម្បីត្រឹមភាគរយតិចតួចក៏ដោយ គឺជាការខាតបង់ផលត្រីជាច្រើនពាន់តោន និងតម្លៃត្រីជាច្រើនលានដុល្លាផងដែរ[20] ។

## កាត់បន្ថយផលប៉ះពាល់នៃទំនប់មកលើទន្លេមេគង្គ

កន្លងមក ទោះជាមានកិច្ចប្រឹងប្រែងនានានៅក្នុងតំបន់នេះហើយក្តី គេពុំទាន់ឃើញមានគំរូនៃវិធានការប្រកបដោយប្រសិទ្ធិភាពដើម្បីកាត់បន្ថយឥទ្ធិពលនៃទំនប់មកលើធនធានជលផលនៅឡើយទេ[9] ។ ការបង្កើតអាងស្តុកទឹកសម្រាប់ជាដែននេសាទ ច្រើនត្រូវបានគេគិតថាជាវិធីមួយដើម្បីទូទាត់នឹងការខាតបង់ ដែលបណ្តាលពីទំនប់។ ប៉ុន្តែយើងដឹងថា នៅក្នុងអាងទន្លេមេគង្គមានត្រីត្រឹមតែប្រាំបួនប្រភេទប៉ុណ្ណោះ ដែលបន្តពូជក្នុងអាងស្តុកទឹក។ ផលនេសាទនៃត្រីទាំងប៉ុន្មានប្រភេទនេះដែលបានពីអាងស្តុកទឹក មិនអាចទូទាត់នឹងការបាត់បង់នៃផលនេសាទសរុបនៅក្នុងទន្លេបានឡើយ។ ការបង្កើតផ្លូវត្រីច្រើនត្រូវបានគេពិពណ៌នាផងដែរថា ជាវិធានការមួយដែលមានសក្តានុពលក្នុងការកាត់បន្ថយផលប៉ះពាល់ ប៉ុន្តែបទពិសោធន៍ជាក់ស្តែងបង្ហាញថា វិធានការនេះនៅមិនគ្រប់គ្រាន់ឡើយ។ នៅក្នុងអាងទន្លេមេគង្គ គេពុំឃើញមានគំរូផ្លូវត្រីដែលមានប្រសិទ្ធិភាពឡើយ[9] ។ មូលហេតុចំបងគឺដោយសារកត្តាអេកូឡូស៊ី និងប្រពលភាពនៃការធ្វើចរាចររបស់ត្រី។ ទិន្នន័យនានាបានឱ្យដឹងថា ការធ្វើចរាចររបស់ត្រីអាចមានដល់ត្រឹមតែ ៣០តោនប៉ុណ្ណោះ ក្នុងមួយម៉ោង នៅតំបន់ខ្លះក្នុងអាងទន្លេមេគង្គ[21] ។ នេះជាបរិមាណដ៏ច្រើនហួសកម្រិតសម្រាប់ត្រីដើម្បីឆ្លងកាត់[22] ។ នៅទំនប់ប៉ាក់មូននៃប្រទេសថៃ បើទោះបីមានសំណង់ផ្លូវត្រីក៏ដោយ សហគមន៍នេសាទទាំងនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម នៃទំនប់នេះបានឱ្យដឹងថា ផលនេសាទបានធ្លាក់ចុះពី ៥០ ទៅ ១០០ ភាគរយ។ ពួកគេក៏បាន

រាយការណ៍ឱ្យដឹងផងដែរថា ពូជត្រីជាច្រើនត្រូវបាត់បង់ជាពិសេសគឺប្រភេទពូជត្រីធ្វើចរាចររយៈឆ្ងាយ និង ពូជត្រីដែលរស់នៅពឹងអាស្រ័យលើវត្តមានទឹកជ្ជូរ[23] ។

## សេចក្តីសន្និដ្ឋាន

ក្នុងករណីអវត្តមានព័ត៌មានលំអិតអំពីគំរូប្លង់ គេមិនអាចធ្វើការវាយតម្លៃពេញលេញ អំពីផលប៉ះពាល់នៃសំណើគម្រោងសង់ទំនប់ដនសាហុង មកលើជលផលក្នុងអាងទន្លេមេគង្គបានឡើយ ។ ទោះជាយ៉ាងណាក៏ដោយការពិនិត្យមើលឡើងវិញនូវព័ត៌មានដែលអាចរកបានបង្ហាញថា សំណើនេះផ្តល់ហានិភ័យខ្ពស់ខ្លាំងណាស់ ។ ទន្ទឹមនឹងនេះក៏មានឧទាហរណ៍ជាច្រើនពីអាងទន្លេនានាដទៃទៀត ដែលបញ្ជាក់ឱ្យឃើញនូវឥទ្ធិពលអវិជ្ជមានបង្កដោយទំនប់មកលើផលនេសាទទឹកសាបនៅតំបន់ត្រូពិកផងដែរ ដោយសារការធ្វើឱ្យរាំងស្ទះផ្លូវធ្វើចរាចរនិងការកែប្រែសណ្ឋានលំហូរទឹកតាមរដូវ[24] ។ ការសិក្សាដើមដំបូងដើម្បីកំណត់អត្តសញ្ញាណ ដែលប្រៀបធៀបចំណូលសេដ្ឋកិច្ចនៃសំណង់ទំនប់ដនសាហុងនៅត្រង់ទីតាំងនេះធៀបនឹងទីតាំងផ្សេងបានកត់សំគាល់ថា គេនៅពុំទាន់បានវាយតម្លៃផលប៉ះពាល់មកលើធនធានជលផលនៅឡើយទេ[25] ។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យអំពីតម្លៃសេដ្ឋកិច្ច នៃជលផលអាងទន្លេមេគង្គ និងអំពីផលប៉ះពាល់របស់ទំនប់នានាមកលើចរាចររបស់ត្រីបានឱ្យដឹងថា ការខាតបង់ផ្នែកសេដ្ឋកិច្ចនៃការបាត់បង់ផលនេសាទអាចមានទំហំធំជាងអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលគេរំពឹងថានឹងបានទទួលពីទំនប់ ។ ការវិភាគនេះបង្ហាញថា ប្រសិនបើសំណើសំណង់ទំនប់នេះត្រូវបានជម្រុញបន្តទៀត គេចាំបាច់ត្រូវមានការសិក្សាទូលំទូលាយតាមបែបវិទ្យាសាស្ត្រ ដើម្បីវាយតម្លៃអំពីការខាតបង់ និងអត្ថប្រយោជន៍ក្នុងបរិបទធំទូលាយនៃ ជលផលក្នុងអាងទន្លេមេគង្គទាំងមូល ។



[1] Vientiane Times, 28 March 2006.

[2] New Straits Times, 4 May 2007.

[3] Maunsell and Lahmeyer Intl. 2004 Power system development plan for Lao PDR. Final report, Volume C: Project catalogue. August 2004. 25 pp.

[4] Daconto, G. (ed.) 2001 Siphandone wetlands. Environmental protection and community development in Siphandone wetlands. Project supported by European Commission. CESVI, Bergamo, Italy. 192 pp.

[5] Baran, E., Baird, I.G., and Cans, G. 2005. Fisheries bioecology at the Khone Falls (Mekong River, Southern Laos). WorldFish Center. 84 pp.

[6] Baird, I.G. 1996 Khone Falls fishers. Catch and Culture (MRC newsletter), vol.2, no. 2, November 1996.

[7] Baran, E. 2006 Fish migration triggers in the Lower Mekong Basin and other freshwater tropical systems. MRC Technical Paper no. 4. Mekong River Commission, Vientiane, Lao PDR. 56 pp.

[8] MRC 2001. Fish migrations and spawning habits in the Mekong mainstream. CD-ROM. Mekong River Commission, Phnom Penh, Cambodia.

[9] Baran, E., Kura, Y., Starr, P. eds. 2007 Influence of built structures on Tonle Sap fisheries. Cambodia National Mekong Committee and the WorldFish Center. Phnom Penh, Cambodia. 44 pp.

[10] Lorenzen, K., Xaypladeth Choulamany, and Sultana P. 2003. Understanding livelihoods dependent on inland fisheries in Bangladesh and Southeast Asia. Lao PDR summary report. WorldFish Center, Penang, Malaysia. 15 pp.

[11] Souvannaphanh B., Chanphendxay S., Choulamany X. 2003. Status of inland fisheries statistics in Lao PDR Pp. 27-32 in FAO (ed.) New approaches for the improvement of inland capture fishery statistics in the Mekong Basin. FAO-RAP publication 2003/1. FAO, Bangkok, Thailand. 145 pp.

[12] LARReC Medium Term Plan 2000-2005. Living Aquatic Resources Research Center. Vientiane, Lao PDR.

[13] STEA 2003. Lao PDR biodiversity: Economic assessment. Science, Technology and Environment Agency, Vientiane, Lao. PDR (mimeo).

[14] Baran, E., Jantunen T., and Chong C.K. 2007. Values of inland fisheries in the Mekong River Basin. WorldFish Center, Phnom Penh, Cambodia. 58 pp.

[15] Meusch, E., Yhoung-Aree J., Friend R., Funge-Smith S.. 2003. The role and nutritional value of aquatic resources in the livelihoods of rural people - a participatory assessment in Attapeu Province, Lao PDR. FAO Regional Office Asia and the Pacific, Bangkok, Thailand, Publication No. 2003/11. 34 pp.

[16] Garaway C. 2005 Fish, fishing and the rural poor. A case study of the household importance of small-scale fisheries in the Lao PDR. Aquatic Resources, Culture and Development, (2) 3-44.

[17] MRC 2005. Annual report of the MRC programme for fisheries management and development cooperation. Mekong River Commission, Vientiane, Lao PDR.

[18] Van Zalinge, N., Degen P., Pongsri Chumnarn, Sam Nuov, Jensen J., Nguyen V.H., and Choulamany X. 2004. The Mekong River system. Pp. 333-355 in R.L. Welcomme and T. Petr (eds.) Proceedings of the Second International Symposium on the Management of Large Rivers for Fisheries, Volume 1. FAO, Bangkok. 356 pp.

[19] Sverdrup-Jensen, S. 2002. Fisheries in the Lower Mekong Basin: Status and Perspectives. MRC Technical Paper nº 6, Mekong River Commission, Phnom Penh, Cambodia. 84 pp.

[20] Baran, E., So S., Kura Y., and Ratner B. 2007 Infrastructure and Tonle Sap fisheries. Policy brief. Cambodia National Mekong Committee and the WorldFish Center. Phnom Penh, Cambodia. 2 pp.

[21] Baran E., Van Zalinge N., Ngor Peng Bun, Baird I.G., Coates D. 2001. Fish resource and hydrobiological modelling approaches in the Mekong Basin. ICLARM, Penang, Malaysia and the Mekong River Commission Secretariat, Phnom Penh, Cambodia. 62 pp.

[22] MRC 2001. MRC Programme for Fisheries Management and Development Cooperation Annual Report 2000/2001. Mekong River Commission, Phnom Penh, Cambodia.

[23] Amornsakchai, S., Annez, P., Vongvisessomjai, S., Choowaew, S., Thailand Development Research Institute (TDRI), Kunurat, P., Nippanon, J., Schouten, R., Sripapatrprasite, P., Vaddhanaphuti, C., Vidthayanon, C., Wirojanagud, W. and Watana, E. 2000. Pak Mun Dam, Mekong River Basin, Thailand. Case Study prepared as an input to the World Commission on Dams.

[24] Kruskopf M. 2007 Impact of built structures on tropical floodplains worldwide. Report of the project "Study of the influence of built structures on the fisheries of the Tonle Sap". WorldFish Center, Phnom Penh, Cambodia. 98 pp.

[25] Mekong Secretariat. 1994. Mekong Mainstream Run-of-River Hydropower: Main Report. A study conducted by Compagnie National du Rhone, Lyon, France in cooperation with Acres International Ltd and Mekong Secretariat Study Team. Published by Mekong Secretariat, Bangkok, Thailand.



WorldFish CENTER

**The WorldFish Center - Headquarters**
P.O. Box 500 GPO, 10670 Penang, Malaysia.
Tel: +(60-4) 626 1606 Fax: +(60-4) 626 5530
Email: worldfishcenter@cgiar.org
**www.worldfishcenter.org**

**The WorldFish Center - Greater Mekong Regional Office**
#35, Street 71 (Corner of Mao Tse Tong Blvd.)
Sangkat Beng Keng Kang I
Phnom Penh, Cambodia
Tel: +855 23 223 208 Fax: +855 23 223 209
Email: worldfish-cambodia@cgiar.org



*Copyright © 2008 WorldFish Center. All rights reserved. This brief may be reproduced without the permission of, but with acknowledgement to, the WorldFish Center.*